Khmer Story Lovers

— ទីស្នាក់ការនៃក្រុមអ្នកនិពន្ធមាតុភូមិ ផ្ទះលេខ ២៩ ផ្លូវលេខ ២៧៨ ដីឡូត៍លេខ ២៩៥ បឹងកេងកង សង្កាត់លេខ ៥ ក្រុងភ្នំពេញ —

## ប្រលោមលោកចេញផ្សាយរៀងរាល់ថ្ងៃ



អ្នកប្រែសម្រួល: អ.គីមសាន

តម្លៃ: 25រ

ផ្សាយចេញពីក្រុមអ្នកនិពន្ធ
«មាតុភូមិ»
ភ្នំពេញ

លេខ ៣៣

ពៅហៃស៊ីពោលថា:

– ពួកយើងបានដឹកស្នូរសិស្សភ្នំទឹកកក បានដឹងទៀតថា គូពីកក្រើនោះលោកខាយក្រុមបានចេញពីកោះ កញ្ញាសរតែម្នាក់ឯងបាត់ហើយ ។ ពួកយើងដឹងថា លោកខាយក្រុមសុខសប្បាយទើបលែងភ័យ ។ សូមសួរលោកខាយក្រុមពីសិស្សភ្នំទឹកកកខ្លះទៅ, តើលោកគប់ពីសម្លាប់ប្តូចឆ៍ឃុំហាន ?

ស៊ីផានសញ្ជ័យតប :

–ម្តាយឪពុកយើងបានដាក់ទោសប្រាប់ថា យើងធ្លាប់ទៅរៀនយុទ្ធសិល្បៈនៅភ្នំទឹកកកកាលពីតូច ហើយសិស្សពាំងកាត់ត្រាជាគ្រូបាផង តើយើងឃុំឃាំងគាត់ម្តេចបាន ? បើត្រូវសម្លាប់ក៏រឹតតែមិនដាច់ចិត្តដែរ ។

ហាពេកាឆ្លើយភ្លាម :

–ក្រុមយើងនិងក្រុមភ្នំទឹកកកមានការព័ន្ធប្រទាញ់ខ្ទះគួរឲ្យស្តាយ, យើងត្រូវ...ត្រូវ...

ខាយបង់ពោលពាក្យមួយឃ្លាដែលមានន័យខ្ពង់ខ្ពស់ ពេលនាយភ្លេចឈប់នៅ ។ ពៅហៃស៊ីជួយឆ្លើយ :

– យើងត្រូវកាឡៃសត្រូវឲ្យក្លាយជាមិត្ត ។

ស៊ីផានសើចយ៉ាងពេញចិត្ត :

- ត្រូវហើយ, កាឡៃសត្រូវឲ្យក្លាយជាមិត្ត ។ ខ្ញុំចង់ដោះលែងពួកនោះទាំងអស់ដើម្បីអញ្ជើញគេមកជប់លៀងរួមគ្នាជាមួយយើងម្តង តើបានឬទេ?

នាយមិនសូវយល់ច្បាប់ទម្លាប់ទើបមិនហ៊ានការកាត់ខ្លួនឯង, ម្យ៉ាងទៀតនាយនឹកថាលោកគ្រូពែនិងសហការីគាត់ទាំងអស់បានខំខ្នះខ្នែងណាស់ ទើបចាប់សិស្សភ្នំទឹកកកបានមកឃុំឃាំង ។

ឥឡូវនាយឮមាត់មួយម៉ាត់ដោះលែងគេទាំងអស់ហាក់ដូចជាច្រើកំណកចង្កាំងពេក ។ មាណពឃើញគេគោរពពេកនាយមិនទាន់អស់សង្ស័យ, មិនហ៊ានទាយថាគេគោរពបញ្ឆោតខ្លួនទេ ។ តែហាស៊ើប :

- លោកនាយក្រុមចិត្តទូលាយណាស់, នេះជាកាយវិការមួយដ៏ប្រសើរលើសលប់ពិតពេញទាំងមូល ។

លោកគ្រូពេទ្យងាកទៅប្រាប់នាយត្រួតរង:

សុំទៅដោះលែងសិស្សភ្នំទឹកកកទាំងនោះមក !

នាយត្រួតនេះទទួលបញ្ជាហើយ ចាត់ឲ្យសហការីបួនរូបនាំសិស្សភ្នំទឹកកក ដែលទើបចាប់បានឡើងមកមុន ។ បុរសទាំងពីរត្រូវគេចងស្លាបសេក, អាវសប្រឡាក់ឈាមដោយអន្ទើបផ្ដាញឲ្យដឹងថា គេបានប្រឡូកគ្នាមួយទឹករួចហានរបួសរៀងខ្លួនស្រេចទៅហើយ ។

នាយត្រួតរងស្រែកគំហក :

- នាំចូលទៅជំរាបសួរលោកនាយក្រុមយើងភ្លាម !

បុរសម្នាក់រាងតាំប៉ប្ដិចបើកភ្នែកក្រឡោតដូចហាំង្ហូរដូចចង់ស៊ីសាច់, ម្នាក់ទៀតអាយុប្រមាណហាសិបឆ្នាំស្រែកជេរខ្លាំងៗ:

- បើឯងក្លាហានចិត្តជាកូនម៉ែឯងសម្លាប់យើងមកចុះ ! ពួកឯងជាក្រុមចោរលើប្រព្រឹត្តតែអំពើយង់ឃ្នងសាងបាបកម្មគ្រប់ពេលវេលា គង់មានថ្ងៃណាលោកគ្រូនាំយើងមកសម្លាប់ឯងផុតពូជខ្ទេចខ្ទីទេ !

ខណៈនោះឮសម្រែកក្រេវក្រោធលាន់ពីក្រៅទៀតថាៈ

- លោកប្អូនដីថ្ងៃថ្មើរមែន ! អីកាចោរប្លន់, អាចង្រៃឧក្រិត, អាឃាតករឃៀរ !

ពួកប្រព័ន្ធទាំង ៧ គឺសិស្សភ្នំទឹកកកប្រមាណម្ភៃនាក់ដើរតាមព្រួនគ្រួងមកពន្ធ្ឹងផ្តល់លៀង ។ ចិនភាន់ផុង, ហ៊ូភាន់យាន, តាន់ភាន់ហួ, ចិភាន់ជិន, វុនភាន់យី និង ហួភាន់ជី ពេមិនរួចពីការធ្លាក់

ដៃក្រមកោះកោះ, សូម្បីរុំនេះរាំនៃយើងដែលបានយុទ្ធសិល្បៈរបស់លោកខ្ពង់ខ្ពស់ ក៏គេមិនផុតដៃ ៗ រុំនេះកាត់ឈរត្រូវកដៅតែងឈប់ហាត់ ដៅហើយដៅទៀត ។ សិស្សខ្លះស្រែកថា:

-លើកក្តារ ទៅត្រូវប្រយុទ្ធគ្នាមួយទល់នឹងមួយមិនត្រូវប្រើជ្រៃសណ្តាប់ដូចក្រុមចោរលួចប្លន់តាមផ្សារទេៗ ជាងនេះធ្វើឲ្យក្រុមហ្វេនយើងហើយមើលមុខគ្នាដឹងថា :

- ចាប់គេមកឃុំឃាំងដោយប្រើវិធីសណ្តាប់នោះមិនមែនជាការបំផ្លែកទេ ៗ

តៃហេស៊ីខ្លាំងណាស់, គ្រាន់តែមើលមុខក៏យល់ចិត្តគេភ្លាម ៗ គាត់ក្រោកពីកៅអីពោលទាំងញញឹម :

- ការលើណេកៈប្រយុទ្ធញ៉ែបពេកយើងបានប្រើជ្រៃសណ្តាប់មែន, តែមិនអាចចាត់ទុកថាយើងខ្ញុំខាងសិស្សឆ្នូវិកកកទេ គឺយើងយល់ដល់ចិត្តភាពរវាងលោកនាយក្រុមស៊ី នឹងត្រូវលោកខាងក្នុងវិកកកប៉ុណ្ណោះទេ, យើងមិនចង់ឲ្យមានការបង្ហូរឈាមរវាងគ្នា ៗ ពេលនេះបើលោកមិនអស់ចិត្តទេ? ពេក៏យ ។ សូមអញ្ជើញចូលប្រយុទ្ធនឹងខ្ញុំម្នាក់ឯងមើល, បើអ្នកណាប្រយុទ្ធនឹងខ្ញុំបានដប់ទៀតខ្ញុំយល់ព្រមទទួលថា ក្រុមឈានល្អជាក្រុមចោរលួចប្លន់តាមផ្សារមែន ៗ

កាលមុនតៃហេស៊ីសំដែងយុទ្ធសិល្បៈប្រាំគុណនឹងប្រាំមួយមុខតែប៉ុន្មានស្លៀក ពួកទាំងនោះជាងមួយលាក់ស់ហើយ ៗ ពេលនេះគាត់ហ៊ានឲ្យផលដប់ស្លៀកយើងឃើញថាគាត់មិនសូវក្រហែនទេ ៗ សិស្សវិកកកប្រុសណាដែលមិនទាន់ស្គាល់ស្នាដៃគ្រូពេទ្យក៏ប្អូលពោះគ្រប់គ្នា, ឥតបើក្លៀតគាត់ប៉ុនរោដៃសក់ឡើយព្រោះឃើញរាងកាយស្គាំងស្គមមានតែស្បែកដណ្តប់ឆ្អឹងហាក់ដូចជាអ្នកជម្ងឺរ៉ាំរ៉ៃយូរឆ្នាំហើយ ៗ គេសើចគ្នាស្រែកថា:

-ក្រុមឈានល្អហ៊ានសំឡុតគេដោយអាងមានគ្នាច្រើនឬ? ផ្ទៃវ៉ានេះគ្មានអ្នកត្រូវឲ្យសរសើរទេ ! កុំថាឡើយត្រឹមដប់ស្លៀក, សូម្បីមួយរយស្លៀកក៏យើងពេចទប់ទល់បានដែរ ៗ

តៃហេស៊ីញញឹម :

- ប្រសើរណាស់, លោកខ្លួចពិតជាក្លាហានអស្ចារ្យមែន ។ យើងព្រលត់គ្នាណា . បើលោកពេចទប់ទល់បានដប់ស្លៀត ក្រុមឈានល្អជាចោរលួចប្លន់តាមផ្សារ, តែបើលោកខ្លួនចាញ់វិញត្រូវក្រុមកកកប្រែក្លាយជាចោរលួចប្លន់, យល់ហើយឬនៅ ?

ពេលចប់លោកគ្រូពេទ្យចូលជិតគ្រាំសដៃគាត់ខ្សែក្លៀវផលចនស៊ីរាំងនាន ម៉ាប់ត្រឹមទ្របសើច

ហេសៗ:

– សូមអញ្ជើញ !

សិស្សក្លឹបកកកឃើញពៅហៃស៊ីស្គមស្លេកស្លាំង ស្រាប់តែគាត់ខ្សែពួរដាច់ដូចកាំបិតគេច្រុះចំកមុខ គ្រប់គ្នាភ័យញ័ររន្ធត់ បាត់សេចក្ដីក្លាហានអស់រលីង ។ ត្បិតកាលនៅជាប់ចំណងគេបានចំប្រឹងចំរើនកម្លាំងសាកល្បងឲ្យដាច់ខ្សែពួរដែរ តែខ្សែនៅជាប់មាំង ។ ក្នុងពេលកំពុងគិតតែងនេះស្រាប់តែមានសម្លេងមួយស្រែកខ្លាំងពីក្រៅថា:

–ប្រសើរណាស់! យើងអាចស្គាល់គ្នាបាន!

សម្លេងនេះធ្វើឲ្យសិស្សក្លឹបកកកសប្បាយរីកមុខគ្រប់គ្នា, សមាជិកក្រុមឈានល្បងស្រឡាំងកាំងហើយពៅហៃស៊ីប្រែទឹកមុខបន្តិចៗ ឮសូរផាំង ! ទ្វារបន្ទប់ជប់លៀងរបើកភ្លាមលេចមនុស្សម្នាក់ដើរចូលមកយ៉ាងរងំអាច គឺអ្នកក្លាហានចិសឧត្តនាមប៉ាយវ៉ាន់ផានតែម្ដង ! គាត់លើកដៃធ្វើគារវកិច្ច:

-ខ្ញុំបាទចង់សុំសាកល្បងនឹងលោកតែបានជប់ស្ទៀត ។

ពៅហៃស៊ីសើចញឹមៗ, ខំលាក់អាកប្បកិរិយា យ៉ាងណាក៏មិនកំបាំងពីភ្នែកសិស្សក្លឹបកកកដែរ ។ ដារ៉ាអៀនខ្មាសបន្តិច ព្រោះគាត់មិនអាចប្រយុទ្ធដណ្ដើមឈ្នះចាញ់ជាមួយប៉ាយវ៉ាន់ផានក្នុងរយៈពេលជប់ស្ទៀតឡើយ, ទាល់តែកប់រយៈស្ទៀត ទើបដឹងសន្លប់ ។ គាត់មានការពិសោធន៍ច្រើន គិតឃើញល្បិចកល យ៉ាងរហ័សទើបឆ្លើយទាំងញញឹម :

– ខ្ញុំអាចស្គាល់លេងជាមួយសិស្សប្អូនលោកគ្រូប៉ាយ ត្រឹមជប់ស្ទៀតបានមែន, តែបើលោកគ្រូអញ្ជើញមកផ្ទាល់ , យើងត្រូវប្តូរការស្គាល់គ្នានេះឲ្យមានន័យផ្សេងទៅវិញ ។ លោកចង់សាកល្បងជាមួយខ្ញុំមិនបាច់កំណត់ចំនួនស្ទៀតទេ ។

ប៉ាយវ៉ាន់ផានសើចហេសៗ:

– ឱ ! សំដីលោកគ្រូដែលស្គាល់គ្នាលេងអម្បាញ់មិញឥតខ្ទឹមសារទេឬ ?

ពៅហៃស៊ីសើចហាសៗ:

– បាទត្រូវហើយ ! ខ្ញុំនិយាយស្គាល់ជប់ស្ទៀតជាមួយជនអន់ខ្សោយនិងមិនចេះគួរសមជាមួយចាស់ទុំប៉ុណ្ណោះ, លោកគ្រូប៉ាយជាមនុស្សប្រភេទនេះដែរ ឬ ?

–ហ៊ឹះ! បើក្រុមឈានល្បងទទួលសារភាពថាខ្លួនជាក្រុមចោរល្មួចប្លន់ដោយថោកទាបតាម ផ្លូវហើយ

Khmer Story Lovers



លោកចង់ចោទខ្ញុំជាមនុស្សអន់ខ្សោយខ្វះការគួរសមក៏ផុតទាស់អ្វីដែរ ។

ក្បួនប៉ាយវ៉ាន់ផានចូលមកដល់ឃើញស៊ីផានអង្គុយលើកន្លែងនាយក្រុមក្រពឹត មុខឡើងរលួងក្រឹតគាត់ ដាប់ពិណរាង់មុខស្រពោនគ្រប់គ្នា , គាត់ក្តៅក្រហាយណាស់ចាប់ផ្ទាត់លោកក្រពៃភ្លាមឲ្យទទួលសារភាពថា ក្រុមឈានល្អប្រព្រឹត្តអំពើចាប់ចោក ។

ក្នុងពេលដែលអ្នកៗទាំងពីរកេតពាក្យដោះស្រាយអៀនខ្លួន គេឮសម្លេងមួយទៀតប្រែពីក្រោមកថា :

យ៉ាន់ឆ្នួនទៅជាស៊ុន, ស៊ីឈីនមិនរុំនយូទៅភូមិបាំងសាំនស៊ី, សុំចូលដឹកបស្តុក្រុមឈានល្អ !

នេះជាសម្លេងក្រអៅនៃស៊ីឈីន ។ ស៊ីផានក្រេកអរណាស់ ស្ទុះរត់ពីកៅអីស្រែកហៅ :

-លោកឪពុក ! អ្នកម្តាយ !

ព្រមទាំងរត់ទៅក្រៅភ្លាម ៗ រត់មកដល់ប៉ាយវ៉ាន់ផាន, ប៉ាយវ៉ាន់ផានក្តៀតធ្មុកាសចាប់ដៃនាយជាប់ កាយវិការនេះរហ័សពេក នាយក្រុមមិនទាន់ក៏ត្រូវប៉ាយវ៉ាន់ផានចុចដីពប់បោនភ្លាម ៗ ។ ប៉ុន្តែ ស៊ីផានចង់ជួបឪពុកម្តាយពេកឥតរវល់គួរសមច្រើន, នាយរលាស់ដៃបញ្ចោញកម្លាំងកាយដ៏ចំឡែក បណ្តាលឲ្យប៉ាយវ៉ាន់ផានស្ទើកមួយចំហៀងខ្លួន ដកដៃចេញវិញយ៉ាងរហ័ស, តែកម្លាំងមាណពក្រិន ក្លាពេក ពាល់តែគាត់ឈានទៅម្ខាងពីរជំហាន ទើបឈរត្រង់ខ្លួនបាន ។

ពៅហៃស៊ីញញឹមយ៉ាងពេញចិត្ត :

- ពិតជាខ្លាំងពូកែមែន !

សំដីនេះមានន័យអួតសរសើរស៊ីផាន ក៏ដូចបង់ពោលចំអកឲ្យប៉ាយវ៉ាន់ផានដែរ ។ មាណព ដើរចូលវិញកាន់ដៃប្តីប្រពន្ធស៊ីឈីនទិនតាចាស់មួយរូបមាឌធំខ្ពស់នៅកណ្តាលផង ។

ក្រុមឈានល្អនៅជិតស្រុកជាស៊ុនទើបស្គាល់តាយ៉ានឆ្នួនគ្រប់គ្នា ។ ពេលឮនាយក្រុមស៊ី ស្រែកហៅប្តីប្រពន្ធស៊ីឈីនថាលោកឪពុកអ្នកម្តាយគេនាំគ្នាក្រោកឈរទទួលយ៉ាងប្រញាប់ ។ ស៊ីផាន កាន់ដៃអ្នកស្រីវុនយូយ៉ាងស្និទ្ធស្នាលជាទីបំផុត, អ្នកស្រីងើបមើលមុខនាយស្ងើចស្រស់ហើយពោលថា :

-ម្សិលមិញកូនទៅណា បាត់ស្រមោលតាំងពីព្រលឹម ធ្វើឲ្យម៉ែភ័យ ? តែពុកឯងមានិយាយថាមិន ងាយនរណាអាចចាប់កូនបានទៀតទេ ។ គាត់ឲ្យយោបល់ថា ត្រូវមកទីតាំងក្រុមឈានល្អស្ទួ ដំណឹងពីកូនណា ! ហេតុនេះបានជាម៉ែអញ្ជើញលោកតាយ៉ានឆ្នួនមកដល់នេះ ម្តាយត្រេកអរណាស់ ។

ចំណែកចិនតុន, គ្រាន់តែឃើញប្ដីប្រពន្ធស៊ីឈីនដើរចូលមក, វាងអៀនក្រហមមុខគេចចេញភ្លាម , តែនាងចំឡែកចិត្តទៀតស្ដាប់តើគេនិយាយពីរនាក់ថាម៉េចខ្លះ ?

ប្ដីប្រពន្ធស៊ីឈីន, យ៉ាងតួន , តៃហៃស៊ីម៉ិនអ្នកក្លាហានមកពីលោកតុនសម្ដីគ្រាយ៉ាងស្និទ្ធស្នាល ក្រៃលែង ព្រោះគេស្គាល់ជាអ្នកក្លាហានដើរចាស់គួរគិតពិតគុណ ។ ម្ចាស់យ៉ៃហួងនិងគ្នាដឹងថា ស៊ីឈីននិង វុនយួជាខ្ញុំពួកម្ដាយស៊ីផាន តើតែគួរសមគិតគោរពគាត់លើសធម្មតា ។ ប្ដីប្រពន្ធស៊ីឈីន ឥតដឹងរឿងមាណពជួយយកសាអ្នកក្លាហានអស់នេះទេ , គាត់ឃើញគេគួរសមក៏ចាក់កំ ស្រឡាញ់រាប់អានគេវិញទៅ ។

ស៊ីផាន់ងាកទៅប្រាប់តៃហៃស៊ី :

-លោកគ្រូតៃ, សូមដោះលែងអ្នកក្លាហានខាងក្នុងចំកុកទាំងអស់ទៅ ។

តៃហៃស៊ីស្រែកខ្លាំង ១ ឲ្យបញ្ជា :

-លោកនាយក្រុមប្រើឲ្យដោះលែងអ្នកក្លាហានខាងក្នុងចំកុក !

គាហាស់ទំពាំងសម្លេងពោលពាក្យ «អ្នកក្លាហាន» ដូចពោលចំអកទៅវិញ, ធ្វើឲ្យក្រុមឈានល្អ ហើរក្រើមខួរតាមក្រោយ :

- លោកនាយក្រុមបញ្ជាឲ្យដោះលែងអ្នកក្លាហានក្នុងចំកុកទាំងអស់ទៅ !

ហើយគេយកសោចាក់ប្រាក់ដៃជើងឲ្យសិស្សក្នុងទីកុកភ្លាម ។ ផ្ទៃយ៉ាងស្ងាត់ជាងទីងល់គាំង, មុខក្រហមឆ្អិន, កាន់ដងដាវស្រែកថា:

- ឈប់សិន ! ស៊ី ... ហ៊ឹះ ! លោកនាយក្រុមស៊ី, លោកគ្រូតៃ ... ពេលនេះមានចាស់ទុំ យ៉ាងខ្ពង់លោកម្ចាស់ភូមិថានស៊ានស៊ូតាំងប្ដីប្រពន្ធស្រាប់, យើងត្រូវដោះស្រាយរឿងមួយ ឲ្យជ្រះស្រឡះ សិន !

គាត់គ្រហែមយកសម្លេងបន្តិច ទើបពោលតទៀតថា :

- យើងជាអ្នកតុននិយម, បើរយមិនឈ្នះគេគឺយើងមានយុទ្ធសិល្បៈអន់ខ្សោយហើយ ។ ពេលនោះគេចង់សម្លាប់ បង់កាប់ពេលយ៉ាងណាស្រេចលើចិត្តគេ ប៉ុន្តែពេលនេះប្អូនរួមគ្រូទាំង អស់សុទ្ធតែត្រូវក្រុមឈានល្អប្រើថ្នាំសណ្ដំចាប់មកឃុំឃាំង ឃើញថា ក្រុមបក្សលោកប្រើមធ្យោបាយ ថោកទាបណាស់ ។ ធ្វើបែបនេះតើខូចកិត្តិយសក្រុមភ្នំចិនកុក ឬ កេរ្តិ៍ឈ្មោះក្រុម

ឈានល្អ ? អប្បាញមិញលោកគ្រូតែងបានប្រសាសន៍ម៉្យាងម្ដេចខ្លះ ? សូមជំរាបអស់លោកទើបមកដល់ថ្មីឲ្យជ្រាបច្បាស់ផងមើល !

តៃហាស៊ីគ្រៃបាម :

–លោកប្អូនប៉ាយ ... :

ប៉ាយវ៉ាន់ផានស្រែកសង្ខាប់ :

–នរណាជាបងប្អូនពួកចោរលួចប្លន់តាមផ្លូវបៀបឯង? ពិតជាគ្មានចេះអៀនខ្មាសមែន!

តៃហាស៊ីធ្វើមិនឮពោលបន្ត :

–លោកនាយក្រុមស៊ីរបស់យើង

ស៊ីឈីងពោលកាត់ភ្លាម :

– លោកគ្រូតៃហ្វា ! កូនប្រុសខ្ញុំនៅក្មេងខ្ចីមិនសមបេះដូងអីទេ ម្ដេចឡើយវាមានសមត្ថភាពល្មមធ្វើនាយក្រុមដឹកនាំអស់លោកបាន ? កាលមុនវាឈ្លោះទាល់តែក្មេងរឿងចាស់អស់ហើយ, ហេតុនេះយើងត្រូវបង្វែរចេញមុខតំណែងនាយក្រុមជាដាច់ខាត ! ខ្ញុំអញ្ជើញអ្នកចាស់ទុំយាងមកកាន់វ៉ាននេះ ដើម្បីដោះស្រាយរឿងហ្នឹងឲ្យប្រះស្រឡះតែម្ដងជាការស្រេច ។

គាត់ងាកពោលទៅកាន់ប៉ាយវ៉ាន់ផាន:

–លោកបងប៉ាយ, រឿងរ៉ាវរវាងក្រុមភ្នំកុកគក និងក្រុមឈានល្អ និងរឿងកូនប្រុសខ្ញុំប្រព្រឹត្តអំពើមិនគប្បីចំពោះក្រុមលោកនោះ សុំផ្អាកទុកមួយអន្លើសិន ដើម្បីដោះស្រាយរឿងតាមច្បាប់ហៃ ។ ខ្ញុំគ្មានឋានៈខ្ពង់ខ្ពស់ក្នុងពិភពគុនមែន, តែខ្ញុំមិនដែលពោលពាក្យកុហកអ្នកណាឡើយ, កូនខ្ញុំនេះពិតជាក្មេងរឿងចាស់អស់រលីងមែន !

គាត់ឈប់មួយខណៈទើបពោលបន្ត :

–ប៉ុន្តែអំពើទាំងឡាយណាដែលបានប្រព្រឹត្តហួសមកហើយ, ទោះវានៅចាំក្ដីមិនចាំក្ដីយើងមិនត្រូវទម្លាក់កំហុសលើអ្នកដទៃទេ ។ ចំណែករឿងគេយកឈ្មោះវាទៅធ្វើឡប់ឡែបប៉ិនប៉ាំងអំពើជោគពាលផ្សេងៗ, ខ្ញុំមិនឲ្យគាត់តាមនឹងវាទេ ។

អ្នកក្លាហាននៅក្នុងបន្ទប់ចាំងមួលស្រឡាំងកាំងគ្រប់គ្នា មិននឹកស្មានថាមានរឿងចម្លែកនេះកើតឡើងសោះ ។ តៃហាស៊ីក្អកខេះៗសួរថា :

-តើលោកបងមានប្រសាសន៍ថាម៉េច? លោកនាយក្រុមស៊ី

ស៊ីផានគ្រវីក្បាលពោលតប:

- ឪពុកខ្ញុំមានប្រសាសន៍ត្រូវណាស់, រូបខ្ញុំមិនមែនជានាយក្រុមនេះរបស់លោកទេ, ខ្ញុំបានប្រកែកជាញឹកញយណាស់តែអស់លោកមិនព្រមជឿសោះ ។

ខណៈនោះហ្វានយីហ្វៃពោលឡើងថា:

- រឿងនេះមានការចិកប៉ុនក្រឹបណាដែរ? ខ្ញុំសុំចូលរួមគួនការដោះស្រាយផងបានទេ? ព្រោះខ្ញុំដឹងច្បាស់ថា នាយក្រុមឈានល្អជាលោកបងគុន ហ្វានមេច្ចក៏ឥឡូវធ្លាក់មកលើលោកបានកុណាស៊ុយទៅវិញ?

តាចាស់ឈ្មោះយាងគួងដែលអង្គុយស្តាប់តែយូរណាស់មកហើយច្បុតគួតហាក់បញ្ឆោតយោបល់ថា:

- សូមលោកប្អូនប៉ាយខាងណេះកុំអន្ទះអន្ទែងពេក, រឿងណាខុសអ្នកណាត្រូវតែរកឃើញក្នុងពេលនេះទេ ឲ្យតែយើងរកឃើញគុណទោសហើយយុត្តិធម៌ ។

យាងគួងចាស់ជរាមែនតែសម្ដីគាត់នៅលានក្រអៅបញ្ញាគំនូរគម្ពីរដាក់បរិបូណ៌និងគិរិយាអង់អាចក្លាហាន គួរឲ្យស្ងើចសរសើរ ។

គាត់ពោលបន្ត:

- រឿងនេះធំហើយទាក់ទងនឹងវិនាសឆ្ងាយណាស់ , បើមិនប្រុងប្រយ័ត្នទេ ។ ដូច្នេះសូមដោះប្រវាក់ដើងដៃជូនសិស្សក្មេងទឹកកកឲ្យអស់សិន ។

សេនាក្រុមឈានល្អបែរមើលទៅហៃហាស៊ីឃើញគាត់ងក់ក្បាល ក៏ស្ទុះស្ទាចទៅដោះប្រវាក់ឲ្យសិស្សក្មេងទឹកកកកល់រូបភ្លាម ។

## វគ្គទី ៣១

## ទឹកចិត្តកូនប្រុស

ប៉ាយវ៉ាន់ជានឈរស្តាប់សំដីស៊ុនលីងនិងយាងគួង មានន័យទោះប្រកាន់ទៅហៃហាស៊ីពេញទី ខុសពីការស្មានរបស់គាត់ក៏បែងយល់អ្វីតែម្តង ។ ក្រោយពីប្អូនការតាំងអស់ត្រូវក្រុមឈានល្អចាប់ឃុំឃាំងធ្វើឲ្យអាម៉ាស់មុខក្រុមក្មួយទឹកកកទាំងមូល ទើបគាត់ចេញមុខប្រយុទ្ធជាមួយហៃហាស៊ីជំនួសប្អូនប្រុស ដោយតាំងចិត្តជាស្រេចថា ទោះត្រូវសាកាប់ចិញ្ច្រាំ ក៏គាត់មិនបុះញញើតត្រូវដែរ ព្រោះគាត់គ្មាន

សង្ស័យឈ្មោះតៃហស៊ីទេ ។

ឥឡូវវត្តមាននៃលោកតាយ៉ានគួននិងម្ចាស់ភូមិហានសាំងស៊ី ធ្វើឲ្យស្ថានការណ៍ប្រែប្រួលអស់រលីង គាត់ត្រូវតែចាំស្លាប់សិន តើតៃហស៊ីដោះស្រាយតាមរបៀបណា ?

ស៊ីឈីងវេងប៉ាសិស្សគុំទឹកកកអង្គុយស្រួលបួលទើបពោលថា :

– លោកគ្រូតៃ, កូនខ្ញុំនៅក្មេងគ្មានបេះដូងអ្វីសោះ លើកឲ្យវាធ្វើនាយក្រុម ដឹកនាំអស់លោកម្តេចបាន ! លោកមិនខ្លាចគេសើចយ៉ាងទេឬ ? ថ្ងៃនេះជួបជុំលោកអ៊ីយ៉ាង, លោកគ្រូម៉ាយ៉ាងឪងបងប្អូនក្តីទឹកកក, មិត្តភក្តិមកពីលាវក្នុងត្រៀបត្រា គួរដោះស្រាយរឿងនេះឲ្យជ្រះស្រឡះទៅ ។ កូនខ្ញុំឈ្មោះស៊ីដុងយ៉ីលែងមានរឿងទាក់ទាបនឹងក្រុមឈានល្អបាប់គាំងពីថ្ងៃនេះតទៅហើយ, តែអំពើផ្សេង ៗ ដែលវាបានប្រព្រឹត្តកន្លងមកវាត្រូវទទួលទាំងអស់ ។ ចំណែករឿងអ្នកដទៃណាយកឈ្មោះវាទៅប្រព្រឹត្តអំពើគ្រប់បែបយ៉ាង ទោះអំពើល្អក៏កូនខ្ញុំមិនបានបុណ្យ, អំពើអាក្រក់ក៏វាមិនត្រូវទទួលផងដែរ ។ មែនទេលោកគ្រូ ?

តៃហស៊ីអេះក្បាលញាប់ដៃហើយសើច :

– ប្រសាសន៍លោកម្ចាស់ទាំងប៉ុន្មានធ្វើឲ្យយើងខ្ញុំជឿជាក់ជាខ្លាំង ។ លោកនាយក្រុមស៊ីទទួលដំណែងនេះបំនួនប៉ីឆ្នាំមកហើយ, មិនមែនទើបនឹងប្រកាសប្រាប់យើងខ្ញុំម្សិលមិញទេណា ? ប៉ុន្តែបានចំណុចមួយដែលយើងមិនដឹងសោះ គឺលោកម្ចាស់ភូមិហានសាំងស៊ីជឿយ៉ាងច្បាស់ត្រូវជាឪពុកម្តាយនាយទៅហ្វាយយើងតែមួយមុខគត់ ។ លោកនាយក្រុម, ហេតុអ្វីលោកមិនប្រាប់យើងខ្ញុំតាំងពីដំបូង ? ភូមិហានសាំងស៊ីនៅជិតទីតាំងក្រុមយើងមួយបន្ទើយសោះ, បើដឹងម្ល៉េះយើងទៅអញ្ជើញលោកប្រុសលោកស្រីមកប្រជុំក្នុងពិធីប្រគល់តំណែងទៅហើយ ។

ស៊ីផានតបតេវហ៊ុប :

– ខ្ញុំ ... ខ្ញុំក៏មិនដឹងដែរ ។

អ្នកទាំងអស់ភ្ញាក់ព្រើត ងាកគ្នាសួរទាំងឆ្ងល់ថា ហេតុអ្វីសាមីខ្លួនមិនដឹងដែរ ?

ស៊ីឈីងពោលបន្ត :

– កាលមុនលោកគ្រូតៃមានប្រសាសន៍ថា កូនខ្ញុំមានជម្ងឺយ៉ាងធ្ងន់ភ្លេចភ្លាំងស្មារតី ភ្លេចកិច្ចការចាស់អស់រលីង, ម៉្លោះហើយរឿងភ្លេចឪពុកម្តាយជាការធម្មតាទៅវិញទេ ។

Khmer Story Lovers



ពៅហៃស៊ីជាប់ចោទឆ្លើយឥតរួចឡើយ ព្រោះក្រុមឈានល្អមានបំណងលើកបន្តុកស៊ីផាន ឲ្យធ្វើនាយក្រុម ដើម្បីទទួលគ្រោះថ្នាក់ជំនួសសមាជិកទាំងអស់មែន, ក្នុងក្រុមឈានល្អទាំងមូលនរណាក៏ដឹងដែរ គ្រាន់តែមិនដែលនិយាយប្រាប់គេ, តើឲ្យគាត់ហែកកេរ្តិ៍ខ្លួនឯងកណ្តាលហ្វូងម៉េចកើត ?

កាលបើឮស៊ីផានពោលអះអាងថាឥតស្គាល់ម្តាយឪពុក គាត់ចាប់ផ្ទាក់ត្រង់នេះឆ្លើយតបភ្លាម :

–លោកនាយក្រុមដែលឈឺម្តងធ្ងន់ផុតជាប់ភ្លេចភាំងស្មារតីអស់មែន តែជម្ងឺនេះកើតមានឡើងប្រហែលពីរខែមុនប៉ុណ្ណោះ ៗ កាលលោកទទួលដំណែងនាយក្រុម លោកមានសុខភាពមាំមួនស្មារតីក៏ស្វាងល្អណាស់, បើមិនដូច្នេះទេលោកប្រយុទ្ធជាមួយនាយក្រុមចាស់ម្តេចនឹងបានកប់វាយស្មើរទាល់តែលោកគុនហ្វានចាញ់ ? ហើយលោកទទួលដំណែងនាយក្រុមដោយរីករាយ ?

ស៊ីឈិងនិងវ៉ុនយូនឿងឆ្ងល់លើសគេ ព្រោះគាត់មិនដែលឮកូននិយាយរឿងនេះប្រាប់សោះ ៗ

អ្នកស្រីសួរភ្លាម :

– កូនប្រុស, រឿង. នេះម៉េចខ្លះ ?

ស៊ីផានគ្រវីក្បាល :

– ខ្ញុំគ្មាននឹកឃើញរឿងហ្នឹងទេ !

ពៅហៃស៊ីថា :

– យើងខ្ញុំគ្រាន់តែដឹងថាលោកនាយក្រុមក្មេងមានត្រកូលស៊ីឈ្មោះផាន ៗ ឯស៊ីជុនយីយើងទើបនឹងឮលោកគ្រូប៉ាយនិងម្ចាស់ភូមិហាំនសាន់ស៊ូពោលថ្មីៗនេះទេ, ឬមួយលោកម្ចាស់ប្រឡូនាយក្រុមយើងខ្ញុំជាកូន ?

វ៉ុនយូគំហក :

–កូនយើងបង្កើតខ្លួនឯងច្រឡំទៅរួចឬ ?

អ្នកស្រីទើបនឹងរកកូនឃើញថ្មីៗ ស្រឡាញ់ស្ទើរលេប ម្តេចនឹងសុខចិត្តឲ្យពៅហៃស៊ីហោចប្រកាន់ផ្តេសផ្តាស ?

ស៊ីឈិងឃើញពៅហៃស៊ីចេះតែរកពាក្យឆ្លើយដោះសារមិនឈប់ឈរ គាត់នឹកថា :

– មើលទៅជាដេកគ្នាយូរមិនដឹងគឺឯណាទេ ៗ

គាត់សួរពៅហៃស៊ីភ្លាម :

- លោកគ្រូពេ,សូមឆ្លើយឲ្យខ្ញុំ ឲ្យត្រង់សមនឹងមនុស្សត្រឹមត្រូវមកមើល? ក្រុមលោកយល់ព្រមលើកកូនខ្ញុំធ្វើនាយក្រុមតាំងក្មេងល្អក់នេះមិនមែនយោលទៅលើគំនិតប្រាជ្ញា កម្លាំងយុទ្ធសិល្បៈឬកិរិយាមារយាទទេ, ក្រុមលោកមានបំណងតែមួយគឺឲ្យរងគ្រោះវេលាស្លាប់ជួបអស់លោកក្នុងពេលបញ្ហាមរណៈលេចរូបកង់ក្នុងពិភពគុនមែនឬទេ ?

សំឡេងនេះប៉ះចំគោលគំនិតពៅហៃសុីផលចំណាក់ទុកយូរឆ្នាំមកហើយ, គាត់មិនអាចលាក់ទឹកមុខបានក្តុកខេះ។បន្ទប់ដើម្បីពន្យារពេលគេគិតពាក្យឆ្លើយដោះសារ ។

ខណៈនោះស្រាប់តែឮសំឡេងសើច ហាស! ហាស:

- អស់លោកកំហាំបញ្ហាមរណៈមកអញ្ជើញដប់ហៀងឬ ? ល្អណាស់, ល្អណាស់ ! ផ្ទាំងបញ្ហាមានទីនេះស្រាប់ហើយ !

ចប់សំដីស្រាប់តែឃើញមនុស្សពីរនាក់ក្រោកឈរភ្លេតក្នុងចំណោមភ្ញៀវ ម្នាក់ស្គម,ម្នាក់ការតភ្លៀក ពាក់យ៉ាងថ្លៃថ្នូរសមរម្យ ។ គេមិនដឹងគេបុរសទាំងពីរចូលតាមណា. មកដល់ពីពេលណាទេ, គួរឲ្យព្រឺក្បាលមែន ។ សុីផពានស្រែកហៅយ៉ាងរីករាយ:

- មកបងទីមួយ, បងទីពីរ... យី ! ខានជួបមុខគ្នាយូរហើយហ្ន៎ ! បងទាំងពីរសុខសប្បាយជាទេឬ ?

សុីឈើងទឹកឃើញរឿងសុីផពានសុំចាង់សានទិនលីសៃធ្វើបងធម៌ ។ ឥឡូវឮនាយហៅបងទីមួយ, បងទីពីរ, គាត់ភ្ញាក់ព្រើតស្រែកថា:

-លោកទាំងពីរអញ្ជើញមកត្រូវពេលណាស់, យើងកំពុងតែដោះស្រាយរឿងនាយក្រុមឈានល្អនេះឯង ។ សុំអញ្ជើញលោកជួយធ្វើសាក្សីក្នុងរឿងនេះផង ។

សុីផពានដើរទៅទទួលចាង់សានទិនលីសៃកាន់ដៃគ្នាយ៉ាងស្និទ្ធស្នាល ។ ចាង់សានសើចហាសៗ:

-អីយ៉ា, ប្អូនប្រុសជានាយក្រុមឈានល្អផង ! អីចឹងៗបានជាខាំងពូកែម៉្លេះហ្ន៎ !

វុងយូជីងជាជីវិតកូនប្រុសសម្លាញ់ត្រូវស្លាប់ស៊ក្នុងគ្រានេះឯង ម៉្លោះហើយគាត់មិនអាចលាក់លៀមឬអត់ធ្មត់ឲ្យនូវកាសល្អកទន្ទឹងផុត ក៏ពោលគាត:

លោកនាយក្រុមឈានល្អនាមគុងហ្វាងទេ, ពួកគេបញ្ឆោតកូនខ្ញុំឲ្យធ្វើនាយក្រុមឲ្យទទួលថ្នាក់មិនអាចយកជាការបានឡើយ ។

ចាន់សានងាកសួរលីសៃ:

- ម៉េច , លោកប្អូនមានយោបល់យ៉ាងណាដែរ ?

លីសៃធ្វើហ៊ឹះ ៗ :

–ចង់ដឹងការពិតត្រូវកម្ចាស់ដើមឲ្យឃើញស៊ិន ៗ

ចាន់សានសើចហេស ៗ ឆ្លើយតបវិញ:

-ត្រូវហើយ ! យើងជាបងប្អូនបានសច្ចាជាប្រួមសុខទុក្ខជាមួយគ្នា , បើគេយកប្អូនប្រុសតៅយើងទៅទទួលទុក្ខជំនួសគេដូច្នេះ គឺគេមើលងាយយើងពេញទីហើយ , យើងមិនសុខចិត្តទេ !

អ្នកក្លាហានទាំងអស់ឃើញចាន់សាននិងលីសៃចូលគ្នីបន្ទប់ត្រូវចិត្តគ្នា ក៏លបមើលមុខស្គាល់ជាក់ជាសេនាបញ្ជាមរណៈកាលពីសាមសិបឆ្នាំមុន គេព្រឺព្រួចខ្លួនគ្រប់គ្នា ឥតហ៊ានហើបមាត់និយាយទេ, សូម្បីពៃហៃស៊ុី ប៉ាយវ៉ាន់ជាងដែលល្បីល្បាញក៏ខ្លាចញញើតដែរ ៗ

ខណៈនោះចាន់សានសើចហាស ៗ :

បងប្អូនយើងពីរនាក់មកអញ្ជើញគេទៅចូលរួមពិធីផឹកស្រាខែកត្តិកជាអំពើល្អសោះ មិនដឹងហេតុអ្វីគេមិនព្រមយល់ចេះតែរុញរាធ្វើឲ្យយើងពិបាកចិត្តគ្រប់ ៗ ពេល, ម្យ៉ាងទៀតយើងអញ្ជើញតែនាយក្រុមបក្សដ៏ល្បីល្បាញក្នុងពិភពគុនផង , អ្នកធម្មតាមិនងាយបានជួបបញ្ហាទេព្រោះផាកស្ពាន់យើងពិបាកពេក ៗ ល្អណាស់, ល្អណាស់ !

ពាក្យ «ល្អណាស់» ចុងក្រោយនេះចាន់សានពោលផង បណ្ដើរខ្សែបត្តុទៅលើប្រាណយ៉ែហ្វ, លិជិងកិង ហ្វុងលានទីងការសានលាងជីដែលសុទ្ធជានាយក្រុមបក្សនៅដំបន់លាវគុងផង ៗ អ្នកទាំងប្អូនព្រឺព្រួចខ្លួនភ្លាម ៗ ចាន់សានសម្លឹងដល់ការសានលាងជីគាត់សើចហាស ៗពោលទៀតថា:

- ល្អណាស់ !

អ្នកទាំងបួនយល់តាំងពីយូរណាស់ហើយថា ក្រុមគាត់ទាំងបួននៅលាវគុងគេចមិនផុតពីការអញ្ជើញទៅផឹកស្រាបបរខែកត្តិកទេ ៗ ពេលនេះចាន់សានពោលពាក្យ « ល្អណាស់ » បីបួនដងបន្តបន្ទាប់គ្នាពិតជាមានន័យថាសេនាបញ្ជាមរណៈជួបគេត្រង់នេះហើយ មិនចាំបាច់ហត់នឿយទៅរកដល់លាវគុងទេ !

ការសានលាងជីស្រែកខ្លាំង ៗ :

- ឯងមើលមុខយើងហើយស្រែកថាល្អណាស់មានន័យថាម៉េច ?

តាំងសានសើចហេស ៗ:

- ល្អណាស់គឺល្អគ្មានន័យអ្វីផ្សេងពីហ្នឹងទេ ។ បើនិយាយឲ្យខ្លីល្អណាស់ផ្ទុយនឹងអាក្រក់ណាស់ ។

ការ៉ាសានលាងជីតំហកទៀត:

- បើចង់សម្លាប់គឺសម្លាប់ភ្លាមមក ! យើងមិនព្រមទទួលផ្កាកញ្ចប់របស់ឯងទេ !

ពេលចប់គ្រាប់សម្ដែងស្ដាំពេលការ៉ាប៉ិតស្ទៀតពីរដើមតម្រង់តាំងសានលាន់ខ្សល់វ៉ៗ ។ ទាំងអស់គ្នាភ្ញាក់ព្រើតមិនស្មានថាគ្រាន់តែចាស់សំដីគ្នាមួយម៉ាត់លោកស្រីពេលការ៉ាប៉ិតតញ្ញើតស្ទេនាទាំងពីរជូចេះឡើយ ។

តាមពិតលោកស្រីការ៉ាសានលាងជីចេះគិតវែងឆ្ងាយណាស់, គាត់នឹកថា បើសេនាទាំងពីរមកដល់ហើយ គ្រោះថ្នាក់គឺមកដល់ដែរ, ហេតុនេះត្រូវតែទុកកាសមានអ្នកក្លាហានជុំគ្នាច្រើនព្រួតដៃគ្នាកំចាត់សត្រូវរួមក្នុងទីនេះតែម្ដងទៅ ។ បើយើងចាប់ផ្ដើមប្រកាសសង្គ្រាមហើយ,ក្រុមឈានល្អ, ក្រុមភ្នំទឹកកកព្រមទាំងម្ចាស់ភូមិហាន សានស៊ូពិតជាមិនឈរចេបដៃមើលបំណាក់ឡើយ ។

ស៊ីផានស្រែកប្រាប់តាំងសាន:

- លោកបងប្រយ័ត្នខ្លួន !

តាំងសានសើចស្រស់:

- មិនអីទេប្អូនពៅ !

គាត់លោសដៃការពេលវត្ថុពណ៌លឿង ១ ពីរទៅទន្ទិចការ៉ាប៉ិតស្ទៀតហោះត្រូវពីរ ១ ហើយវត្ថុពីរនោះក្រឡាស់ខ្លួនទៅទ្រការ៉ាប៉ិត ដូចជាស ហើយវត់វិលទៅរកម្ចាស់ដើមវិញភ្លាម ។ គ្រាន់តែប្រសម្មេងប៉ះទង្គិចគ្នា គឺអាចចាយបានថាតាំងសានមានកម្លាំងដល់កម្រិត, ប៉ុន្តែការ៉ាសានលាងជីទទួលបានជោគជ័យ វត្ថុទាំងពីរនេះការ៉ាប៉ិតច្បាស់ជាជ្រុលជំពេលទៅត្រូវមិត្តភក្ដិក្រោយខ្នង ដោយគ្រោះមិនខាន ។ លោកស្រីត្រូវតែលូកដៃទទួលវត្ថុទាំងពីរជាដាច់ខាត ។ លោកស្រីទទួលដល់ដៃភ្លាមគឺឈឺស្ពឹកដល់ស្មាភ្លាមរហូតដងខ្លួនមួយចំណែកខាងលើទៀត ។ លុះចុះមើលវត្ថុពណ៌លឿងក្នុងដៃទើបលោកស្រីដកដង្ហើមធំភ្ញាក់ក្រញាញ់ញ័រទ្រូងឱបឆាក់ ព្រោះវត្ថុដែលទ្រការ៉ាប៉ិតគាត់ជាផ្កាកស្ពាន់បញ្ចាមរណៈដែលអ្នកគុននិយមកល់រូបខ្លាចរអានោះឯង ។

Khmer Story Lovers



លោកស្រីជីនរៀនបញ្ជាមរណៈច្បាស់លាស់ណាស់, ឲ្យតែអ្នកណាទទួលផ្កាកស្លាក់គេគាបចាត់ទុកជាអ្នកនោះយល់ព្រមទៅរួមពិធីជប់លៀងបបរខែកត្តិកហើយ, ហើយអ្នកនោះឯងមិនត្រូវជំទាស់ទៀត។ លោកស្រីគ័យតក្កមាទិកមុខឡើងស្លាំងរកឈាមមួយតំណក់គ្មាន, ដងខ្លួនគាត់ញ័រចំប្រប់ៗ គាត់ស្រែកស្អកថែសៈ

–ហាស! ហាស! ឲ្យយើងទៅ.. ស៊ុបបរ...ខែកត្តិក!

កថានេះមានន័យល្អ័ងជួរចត់ធ្វើឲ្យអ្នកទាំងឡាយស្រងូតស្រងាត់ជាមួយគាត់ដែរ ៗ

ចាងសានស្រែកហេសាៗដដែលៈ

– គឺលោកគ្រូតែ, លោកល្អងលោមប្អូនប្រុសពៅខ្ញុំឲ្យជាប់អន្ទាក់លោកឲ្យធ្វើខាយក្រុម ៗ ប្អូនខ្ញុំជាមនុស្សស្លូតត្រង់ចិត្តល្អពេកបានជាញុកលក្រុមលោកហើយ, តែយើងខ្ញុំពីរនាក់ជាបងមិនមែនមនុស្សស្លូតត្រង់ត្រឹមត្រូវទេ, កាលណាយើងចេញមុខមកអញ្ជើញភ្ញៀវយើងស៊ើបសួរឲ្យបានច្បាស់លាស់ជាមុនសិន, អញ្ជើញមនុស្សខុសឲ្យគេស្លាប់ទទេៗ យើងមិនដែលធ្វើឡើយ ៗ ញុះ! បើខុសមនុស្សមែន, ចាងសាននិងលីសែរយើងនេះមិនដឹងយកមុខទៅទុកឯណាទេ! នែប្អូនប្រុស, ដល់ពេលអញ្ជើញអ្នកទទួលខុសត្រូវខាងក្រុមឈានលួមកហើយឬ ?

លីសែងកក្បាលៈ

– ល្មមហើយ! ដល់ពេលហើយ!

លីសែចាប់កៅស៊ូមួយៗ គីរប៉ោះវ៉ុវទៅលើដំបូលផ្ទះឮគ្រាំងៗព្រោះ! ដំបូលបែកធ្លាក់មួយប្រឡោះធំធ្លាក់កំទេចផ្ទះភ្ញៀវនិងវត្ថុមួយដុំមូលធំរមៀលចុះមកឮគ្រូស! កណ្តាលបន្ទប់ជប់លៀង ៗ ទាំងអស់គ្នាថយក្រោយក្រោកៗ បើកភ្នែកក្រឡង់ ព្រោះវត្ថុដែលទើបធ្លាក់មកក្រោយគេជាដងខ្លួនមនុស្សម្នាក់រមួលក្រញាំៗ!

លីសែលូកម្រាមដៃស្រាយដីពចរដងនៅពីចម្ងាយ, ម៉ងយូវប៉ុន្មានគេក្រោកឈរសន្សឹមៗលើកដៃញីភ្នែកក្រឡេកមើលឆាយកាយដូចទើបភ្ញាក់ពីដេក ៗ

ភ្លាមនោះគេភ្ញាក់ផ្អើលឡូឡាពេញបន្ទប់, អ្នកខ្លះស្រែកថាៈ គាត់ ... គាត់ ...

– ម៉េចអ៊ីចឹង ?

– ចាំស្លូកមែន! ចម្លែក ..

លីសែ យារទ្រាមដៃទម្លាយដីពទេជនមកដល់ក្រោយនេះ តាមស្នៀតដ៏ពិសិដ្ឋដែលធ្លាប់ត្រូវគេនិយាយក្នុងពិភពលោកតែមិនដែលបានឃើញផ្ទាល់ភ្នែក ម្ល៉ោះហើយគេភ័យរន្ធត់គ្រប់គ្នា បែរទៅមើលបុរសម្នាក់របូតពីអំបូលផ្ទះភ្លាម ៗ គេញីក្បាលសំពោងបើកភ្នែកក្រឡន់ ព្រោះបុរសស្លៀកពាក់ស្អាតបាតមុខមាត់ស្រស់សង្ហាដូចស៊ីផានបេះបិទ ! នៅលើម្លូកគេមានដាំពេជ្រមួយគ្រាប់ភ្លឺចិញ្ចាចសមជាអ្នកថ្ងៃថ្នូរមានពូជពង្សខ្ពង់ខ្ពស់មែន !

ចាន់សានស្ញើចហស១ពោលថា :

-លោកនាយក្រុមស៊ី ! យើងមកសុំអញ្ជើញលោកទៅជប់លៀងបបរខែកត្តិក, លោកទៅទេ ?

ពោលចប់គាត់លូកយកផ្កាគស្មាន់ពីមេកកាន់នៅដៃ ។ ស៊ីផានសួរដោយមិនចាំង :

- លោកបង.. រឿងនេះយ៉ាងម៉េច ?

ចាន់សានញញឹម :

- ប្អូនប្រុសមើលមុខជននេះមើល៍, ដូចប្អូនឯងបេះបិទឬទេ ? គេនាំបុរសនេះទៅលាក់ទុកមួយកន្លែងដ៏ស្ងាត់ ហើយដាក់អន្ទាក់ចាប់ប្អូនឯងមកធ្វើនាយក្រុមជំនួសគេ ។ ឥឡូវ, ហាស១.. បងរកគេឃើញហើយ បងមិនឲ្យប្អូនធ្វើនាយក្រុមតទៅទៀតទេ ! ប្អូនខឹងនឹងបងឬ ?

ស៊ីផានគ្រវីក្បាលហើយទំសម្លឹងជនមួយនោះ តាំងពីក្បាលដល់ចុងជើង ។ មួយសន្ទុះធំទើបពោល :

- ម៉ែ, ពុក, ទីង១ គុង១, លោកគ្រូពៃ, ខ្ញុំបានប្រាប់រួចហើយ... ថាអស់លោកច្រឡំ, ឥឡូវឃើញទេ, គាត់ជានរណា, ខ្ញុំជានរណា ?

វុនយូស្ទុះចូលទៅជិតសួរបុរសមកថ្មី ដោយសម្លេងញ័រ ៗ :

- ឯងជាកូនយើងឬ ?

បុរសនោះងក់ក្បាល :

- បាទ ! ម៉ែនិងពុកអញ្ជើញមកទីនេះដែរឬ ?

ខណៈនោះប៉ាយ៉ុភន់ជានចូលទៅសួរដោយទឹកមុខម៉ាះ:

- ឯងនៅស្គាល់មុខយើងទេ ?

បុរសទូនមុខចុះ ឆ្លើយយ៉ាងស្រងូត:

- គ្រូមាប៉ាយ, គ្រូ... គ្រូមាទាំងអស់អញ្ជើញមកធ្វើអីដែរ ?

ប៉ាយរាំងជុនសើចក្អាកក្អាយ:

- ហាស ! ហាស ! ពួកយើងមកទាំងអស់គ្នាគ្មានសល់ម្នាក់ទេ !

តៃហេស៊ីជ្រួញចិញ្ចើមពោលមួយៗ :

- អ្នកទាំងពីរមុខមាត់ដូចគ្នាបេះបិទ, អាយុក៏ស្របាលគ្នា, រាងរៅដូចគ្នាទៀត ! អ្នកណាមិនច្រឡំ ? តើលោកណាមួយជានាយក្រុមយើងខ្ញុំ ? ខ្ញុំមើលមិនច្បាស់ទេ ។ ហ៊ឺ ! កូនលោកយើងនេះមានរឿងចម្លែកបែបហ្នឹងដែរឬ ? លោក . . . លោកខាងណោះជានាយក្រុមពិតប្រាកដរបស់ពួកយើងឬ ?

បុរសងក់ក្បាលជំនួសចម្លើយ: តៃហេស៊ីសួរទៀត:

- ចុះប៉ុន្មានខែនេះលោកនាយក្រុមអញ្ជើញទៅណាបាត់ ?

បុរសសង្ហាពោលដោយស្រងូត:

- ហ៊ឺ ! រឿងនេះវែងឆ្ងាយណាស់, ចាំនិយាយគ្នាក្រោយ ។

ក្នុងបន្ទប់ជប់លៀងទាំងមូលគ្មាននរណាហាមាត់និយាយស្ដីឡើយ, អ្នកស្រីវុនយូយំខ្សឹកខ្សួលក្បែរកូន...

មួយសន្ទុះធំទើបប៉ាយរាំងជុនពោល :

- មុខមាត់, រាងរៅដូចគ្នាបាន, ចុះស្នាមរបួសលើដើមទ្រូងក៏ដូចគ្នាដែរ? រឿងនេះចម្លែកណាស់ !

ចិនតុងក្រាំមិនបានស្រែក :

- គាត់នេះក្លែងក្លាយទេ, បើជាមែនវាមិនមានស្នាមរបួសលើស្មាឆ្វេង ..ស្នាមព្រួញ..

ស៊ុឈ័ងសង្ស័យដែរប្រកាសថា :

- កូនខ្ញុំមានស្នាមសាក់ប្រាក់កាក់ហោលត្រូវពីតូចលើកំភេះគូទ !

គាត់ចង្អុលស៊ីផានពោលបន្ត:

- ទៅលើខ្លួនកូននេះមានស្នាមសាក់សម្គាល់ . សូមពិនិត្យមើលទៅនឹងដឹងច្បាស់ថា មួយណាក្លែងក្លាយមួយណាពិតប្រាកដទេ ។ (នៅមានត)



Khmer Story Lovers